Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ដឹងពីហានិភ័យនៃទឹកជំនន់ របស់អ្នក



## ស្វែងយល់អំពីហានិភ័យនៃទឹកជំនន់ របស់អ្នក

- ទាក់ទងសាលាសង្កាត់របស់អ្នកសម្រាប់ព័ត៌មាននៅតាមមូលដ្ឋានអំពីហានិភ័យទឹកជំនន់របស់អ្នក។
- ទាក់ទង ផ្នែក NSW SES នៅក្នុងតំបន់របស់អ្នកសម្រាប់ ព័ត៌មានអំពីទឹកជំនន់នៅតាមមូលដ្ឋាន។
- និយាយជាមួយអ្នកជិតខាង និងអ្នកស្នាក់នៅក្នុងតំបន់ដែលបានរស់នៅ ធ្វើការ ឬមកលេងនៅតំបន់នោះអស់រយៈពេលជាយូរមកហើយ ដើម្បីទទួលបានព័ត៌មានអំពីទឹកជំនន់ដែលមានក្នុងប្រវត្តិសាស្ត្រ។
- ស្រាវជ្រាវមើលពីកម្ពស់ផ្ទះ អាជីវកម្ម ឬទ្រព្យសម្បត្តិរបស់អ្នកដែលអាចរងផលប៉ះពាល់ដោយទឹកជំនន់។
- ត្រូវប្រាកដថាអ្នកមានគោលការណ៍ធានារ៉ាប់រងត្រឹមត្រូវដើម្បីធានាលើការខូចខាតដោយទឹកជំនន់សម្រាប់ផ្ទះ និងទ្រព្យសម្បត្តិរបស់អ្នក។

## ត្រូវដឹងអំពី ផលប៉ះពាល់នៃទឹកជំនន់

ការខូចខាតដល់ផ្ទះ អាជីវកម្ម ឬទ្រព្យសម្បត្តិរបស់អ្នក

ការដាច់ថាមពល និងការផ្គត់ផ្គង់ទឹក

ការបាត់បង់ការតភ្ជាប់ទំនាក់ទំនង

ការខូចខាតដល់ប្រព័ន្ធលូបង្ហូរទឹក

ទឹកជំនន់លើផ្លូវ ស្ពាន និងកន្លែងនានាដែលអ្នកទៅលេង

ការនៅដាច់ពីគេឯង។ ទោះបីជាទ្រព្យសម្បត្តិរបស់អ្នកមិនបានជន់លិចក៏ដោយ ក៏អ្នកអាចត្រូវបានហ៊ុំព័ទ្ធដោយទឹកជំនន់ដែរ។

## ដឹងពីអ្វីដែលត្រូវធ្វើ និងកន្លែងដែលត្រូវទៅ



រៀបចំផែនការចាកចេញឱ្យបានមុន។



ចែករំលែកផែនការសង្គ្រោះបន្ទាន់របស់អ្នកជាមួយគ្រួសារ អ្នកជិតខាង និងសហការី ហើយពិនិត្យវាឡើងវិញជាប្រចាំ។



រៀបចំផែនការសម្រាប់ផ្លូវធ្វើដំណើរដែលមានសុវត្ថិភាពសម្រាប់សេណារីយ៉ូនៃការបិទផ្លូវផ្សេងៗគ្នា។




## ត្រូវដឹងព័ត៌មាន

ទាញយកកម្មវិធីគ្រោះថ្នាក់នៅជិតខ្ញុំ **Hazards Near Me** app ដាក់ក្នុងឧបករណ៍ចល័តរបស់អ្នក និងបង្កើត **តំបន់ឃ្លាំមើល** សម្រាប់តំបន់នានាដែលអ្នករស់នៅ ធ្វើការ និងទៅទស្សនា។

ក្នុងស្ថានភាពគំរាមកំហែងដល់ជីវិត **ហៅទូរសព្ទទៅលេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES